ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ ០៣៥.....សហវ. សអ

រាជធានីភ្នំពេញ ថ្ងៃទី ០៩ ខែ ធ្នូ ឆ្នាំ ២០១០

# សេចក្តីសម្រេច
## ស្តីពី
## ការបង្កើតអនុគណៈកម្មការវាយតម្លៃដីមិនបានប្រើប្រាស់ ខេត្តប៉ៃលិន

## ប្រធានគណៈកម្មការវាយតម្លៃដីមិនបានប្រើប្រាស់

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស.រកត.០៩០៨.១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ ១១/នស/៩៤ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ១៩៩៥
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២៩៧/០៣ ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសារពើពន្ធ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៦/០៣៥ ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០០៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ២០០៧
- បានឃើញអនុក្រឹត្យលេខ ០៥៨ អនក្រ ចុះថ្ងៃទី២៥ ខែកក្កដា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតគណៈកម្មការវាយតម្លៃដីមិនបានប្រើប្រាស់

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom , khan Daun Penh, Phnom Penh, CAMBODIA.
www.mef.gov.kh
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798
mef_adm@yahoo.com

- បានឃើញអនុក្រឹត្យលេខ ១៣៤ អនក/បក ចុះថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតម្លើងទីចាត់ការគយ និងរដ្ឋាករ នាយកដ្ឋានពន្ធដារ និងរតនាគារជាតិ នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ឱ្យទៅជាអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា អគ្គនាយកដ្ឋានពន្ធដារ និង អគ្គនាយកដ្ឋានរតនាគារជាតិ ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញប្រកាសលេខ ២២៤ ប្រក.សហវ.ពដ ចុះថ្ងៃទី០៥ ខែកក្កដា ឆ្នាំ១៩៩៦ ស្តីពីការប្រមូលពន្ធលើដីធ្លីមិនបានប្រើប្រាស់
- បានឃើញសេចក្តីសម្រេចលេខ ០០៤ សសរ.សហវ.ពដ ចុះថ្ងៃទី២៤ ខែសីហា ឆ្នាំ១៩៩៨ ស្តីពីការប្រមូលពន្ធលើដីធ្លីមិនបានប្រើប្រាស់
- បានឃើញប្រកាសលេខ ០៦៧ សហវ.ប្រក.ពដ ចុះថ្ងៃទី០៦ ខែមករា ឆ្នាំ២០០៩ ស្តីពីការតែងតាំងសមាសភាពគណៈកម្មការវាយតម្លៃដីមិនបានប្រើប្រាស់
- បានឃើញសំណើលេខ ៦៥៣ លស.បល ចុះថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១០ របស់សាលាខេត្តប៉ៃលិន ស្តីពីការស្នើសុំកែសម្រួលសមាសភាពអនុគណៈកម្មការវាយតម្លៃដីមិនបានប្រើប្រាស់
- យោងតាមការងារចាំបាច់ក្នុងការប្រមូលពន្ធលើដីធ្លីមិនបានប្រើប្រាស់ នៅខេត្តប៉ៃលិន ។

## សម្រេច

**ប្រការ ១.-** បង្កើតអនុគណៈកម្មការវាយតម្លៃដីមិនបានប្រើប្រាស់នៅខេត្តប៉ៃលិន ដែលមានសមាសភាព ដូចខាងក្រោម :

| | | |
|---|---|---|
| ១. ឯកឧត្តម អៀង ទុន | អភិបាលរងនៃគណៈអភិបាលខេត្ត | ប្រធាន |
| ២. លោក ហ៊ុក សុផល | ប្រធានមន្ទីររៀបចំដែនដីនគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្ត | អនុប្រធាន |
| ៣. លោក អ៊ុក សារិន | ប្រធានសាខាពន្ធដារខេត្ត | អនុប្រធានប្រចាំការ |
| ៤. លោក រាម សុមាន | ប្រធានមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុខេត្ត | សមាជិក |
| ៥. លោក ផាន់ ពេជ្រ | ប្រធានមន្ទីរកសិកម្មខេត្ត | សមាជិក |
| ៦. លោក យឹម ឡាំង | អភិបាលនៃគណៈអភិបាលស្រុកសាលាក្រៅ | សមាជិក |
| ៧. លោក សួស ស៊ីយ៉ាត | អភិបាលនៃគណៈអភិបាលក្រុងប៉ៃលិន | សមាជិក |
| ៨. លោក រស់ ឡឿន | នាយទីចាត់ការអន្តរវិស័យខេត្ត | សមាជិក |

**ប្រការ ២.-** អនុគណៈកម្មការមានភារកិច្ច :

- ផ្សព្វផ្សាយជាសាធារណៈនូវច្បាប់ស្តីពីការប្រមូលពន្ធលើដីធ្លីមិនបានប្រើប្រាស់
- បង្កើតបញ្ជីដីត្រូវជាប់ពន្ធតាមតំបន់ក្នុងខេត្ត
- លើកគម្រោងតម្លៃដីក្នុងមួយម៉ែត្រក្រឡា គិតតាមតំបន់នីមួយៗក្នុងខេត្ត ដើម្បីជាមូលដ្ឋានគណនាប្រាក់ពន្ធដាក់ជូនគណៈកម្មការវាយតម្លៃដីមិនបានប្រើប្រាស់ ពិនិត្យ និងសម្រេច
- ផ្តល់មតិចំពោះរឿងវិវាទនានា ដែលពាក់ព័ន្ធទៅនឹងដីមិនបានប្រើប្រាស់ ។

…/…

**ប្រការ ៣.-** អនុគណៈកម្មការអាចរៀបចំបង្កើតក្រុមជំនួយការមួយ ដើម្បីធានានិរន្តរភាពក្នុងប្រតិបត្តិការរបស់អនុគណៈកម្មការ ។

**ប្រការ ៤.-** សមាជិកអនុគណៈកម្មការ ត្រូវចូលរួមធ្វើការងារ និងប្រជុំតាមសេចក្តីអញ្ជើញរបស់ប្រធានអនុគណៈកម្មការ ។

**ប្រការ ៥.-** អនុគណៈកម្មការត្រូវចូលរួមធ្វើការងារ និងប្រជុំតាមសេចក្តីអញ្ជើញរបស់ប្រធានគណៈកម្មការ និងត្រូវរាយការណ៍ជាប្រចាំតាមខែនីមួយៗ មកគណៈកម្មការវាយតម្លៃដីមិនបានប្រើប្រាស់នៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

**ប្រការ ៦.-** សេចក្តីសម្រេចណាដែលផ្ទុយពីសេចក្តីសម្រេចនេះ ត្រូវទុកជានិរាករណ៍ ។

**ប្រការ ៧.-** ឯកឧត្តម លោក-លោកស្រី ដូចមានរាយនាមក្នុងប្រការ១ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

**ប្រធានគណៈកម្មការវាយតម្លៃដីមិនបានប្រើប្រាស់**

**គង់ វិបុល**

**រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

<u>កន្លែងទទួល</u> :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ក្រសួងស្ថាប័នកណ្តាល
- សាលាខេត្តប៉ៃលិន *"ដើម្បីជូនជ្រាបជាព័ត៌មាន"*
- ដូចប្រការ៧ *"ដើម្បីអនុវត្ត"*
- ឯកសារ-កាលប្បវត្តិ